# មត៌កវប្បធម៌អរូបីកម្ពុជាទាំង៧ ចុះក្នុងបញ្ជីអង្គការយូណេស្កូ

*មត៌កវប្បធម៌អរូបី ឬបេតិកភណ្ឌវប្បធម៌អរូបី សំដៅលើជំនឿ កិច្ចប្រតិបត្តិ សិល្បៈសម្តែង ចំណេះជំនាញប្រពៃណី ដែលសហគមន៍នីមួយៗទទួលស្គាល់ថាជាទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។ មរតកវប្បធម៌អរូបីទាំងនេះ បានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយ ហើយត្រូវសហគមន៍ ឬក្រុមមនុស្សយកមកប្រតិបត្តិឡើងវិញរហូតមក ដើម្បីឆ្លើយតបទៅនឹងបរិស្ថានរស់នៅ ចំណេះដឹងប្រពៃណីទាក់ទងនឹងធម្មជាតិ និងប្រវត្តិរឿងរ៉ាវរបស់ពួកគេ ព្រមទាំងផ្តល់ឲ្យសហគមន៍នោះនូវអត្តសញ្ញាណ និងនិរន្តរភាពផង។ ទន្ទឹមនោះ ការសិក្សាស្វែងយល់ដឹងពីមត៌កវប្បធម៌អរូបីតាមសហគមន៍ផ្សេងៗគ្នា ជួយឲ្យមានកិច្ចសន្ទនាជាអន្តរវប្បធម៌ ព្រមទាំងជំរុញឲ្យមានការគោរពនូវទំនៀមទម្លាប់រស់នៅរបស់គ្នាទៅវិញទៅមក។*[1]

*បច្ចុប្បន្ន(គិតត្រឹមការចុះបញ្ជីចុងក្រោយក្នុងឆ្នាំ២០២៤) កម្ពុជាមានមោទនភាពបំផុតដែលបានចុះបញ្ជីមត៌កវប្បធម៌អរូបី ចំនួន៧ទម្រង់ ក្នុងបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិរបស់អង្គការយូណេស្កូ (UNESCO's Representative List of the Intangible Cultural Heritage of Humanity) ដូចខាងក្រោម៖*

## ១. របាំព្រះរាជទ្រព្យ (៧ វិច្ឆិកា ២០០៣)

*របាំព្រះរាជទ្រព្យ គឺជាទម្រង់របាំបុរាណ និងជាសិល្បៈសក្តារៈខ្ពង់ខ្ពស់ក្នុងវប្បធម៌ខ្មែរ។ របាំនេះមានឈ្មោះហៅផ្សេងទៀតដូចជា ល្ខោនព្រះរាជទ្រព្យ ឬហៅម្យ៉ាងទៀតថា ល្ខោនហ្លួង ដ្បិតតែងបានការសន្តោសទំនុកបម្រុងពីព្រះមហាក្សត្រ ព្រះរាជវង្សានុវង្ស ហើយតែងសម្តែងក្នុងព្រះរាជពិធីសំខាន់ៗដូចជា ព្រះរាជពិធីគ្រងរាជ្យសម្បត្តិ ព្រះរាជពិធីតាំងតុ ព្រះរាជពិធីចម្រើនព្រះជន្ម ព្រះរាជពិធីបុណ្យអុំទូក និងពិធីទទួលស្វាគមន៍ប្រតិភូ។ របាំនេះសម្តែងដោយមនុស្សស្រីទាំងអស់ លើកលែងតែតួស្វា តួត្មុក តួឥសី និងតួអង្គសត្វនានាទៅតាមសាច់រឿងដែលលើកមកសម្តែង។*

---

[1] *សូមអាន៖* *Basic Texts of the 2003 Convention for the Safeguarding of the Intangible Cultural Heritage, UNESCO*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*



រូបលេខ១ របាំព្រះរាជទ្រព្យសម្តែងរឿងរាមកេរ្តិ៍ អន្ទើព្រះរាមដើរទេស

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៣ របាំព្រះរាជទ្រព្យ ត្រូវបានប្រកាសទទួលស្គាល់ដោយអង្គការយូណេស្កូថាជា "ស្នាដៃវិចិត្រនៃបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិ" ហើយនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របាំនេះបានបញ្ចូលក្នុង"បញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ ក្នុងកិច្ចប្រជុំលើកទី៣ នៃគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី នៅទីក្រុងអ៊ីស្តែនប៊ុល ប្រទេសទួរគី។

## ២. ល្ខោនស្រមោលស្បែកធំ (២៥ វិច្ឆិកា ២០០៥)

ល្ខោនស្រមោលស្បែកធំ ឬហៅខ្លីថាល្ខោនស្បែកធំ ក៏ជាទម្រង់សិល្បៈសក្ការៈដូចរបាំព្រះរាជទ្រព្យដែរ។ ល្ខោនស្បែកធំ សម្តែងតែអន្ទើនានាក្នុងរឿងរាមកេរ្តិ៍ ដោយប្រើផ្ទាំងស្បែកធំៗឆ្លាក់តួអង្គដូចជា ទេព យក្ស មនុស្ស សត្វ រុក្ខជាតិ សំណង់ និងអ្វីៗទៅតាមសាច់តាមសាច់រឿង។ ពិធីដែលធ្លាប់សម្តែងស្បែកធំមានដូចជា ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រ-ព្រះញាតិវង្ស ព្រះសពសម្តេចព្រះសង្ឃរាជ ព្រះចៅអធិការវត្ត និងព្រះរាជពិធីគ្រងរាជសម្បត្តិ ចម្រើនព្រះជន្មព្រះមហាក្សត្រ ឬបញ្ចុះសីមា ។ល។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ២ ល្ខោនស្បែកធំសម្តែងរឿងរាមកេរ្តិ៍ អន្ទើចម្បាំងឥន្ទ្រជិត*

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ល្ខោនស្រមោលស្បែកធំ បានចុះក្នុងបញ្ជីអង្គការយូណេស្កូថាជា "ស្នាដៃពិចិត្រនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ" ហើយនៅឆ្នាំ២០០៨ ល្ខោនស្បែកធំនេះបានប្តូរទៅក្នុង "បញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ" ស្របពេលនឹងរបាំព្រះរាជទ្រព្យ។

## ៣. ល្បែងទាញព្រ័ត្រ (២ ធ្នូ ២០១៥)

ទាញព្រ័ត្រក្នុងសង្គមខ្មែរ ពុំមែនត្រឹមជាល្បែងសម្រាប់ល្បងកម្លាំងគ្នាទេ តែល្បែងនេះមានខ្លឹមសារ និងអត្ថន័យជ្រាលជ្រៅទៅក្នុងជំនឿ។ ក្នុងជំនឿខ្មែរ ទាញព្រ័ត្រជាល្បែងសម្រាប់លេងជាទូទៅក្នុងពិធីបុណ្យចូលឆ្នាំ និងលេងក្នុងបរិបទជា "កិច្ច" ក្នុងពិធីឆ្លងចេត្រ ឬឡើងអ្នកតានៅតាមបណ្តាសហគមន៍មួយចំនួនក្នុងខេត្តសៀមរាប និងកំពង់ធំ ប្រារព្ធក្រោយចូលឆ្នាំ ឬមុនចូលរដូវធ្លាក់ភ្លៀងធ្វើស្រែចម្ការ។ ថ្ងៃចុងក្រោយនៃថ្ងៃចូលឆ្នាំ ជាថ្ងៃ "ផ្តាច់ព្រ័ត្រ" ពោលគឺគេត្រូវទាញព្រ័ត្រឲ្យដាច់នៅវេលាថ្ងៃត្រង់ ដែលខ្លឹមសារជារួមក្នុងគំនិតខ្មែរ គឺមានន័យថា ផ្តាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មី។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៣ ល្បែងទាញព្រ័ត្រលេងក្រោយចូលឆ្នាំ នៅសហគមកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល

ល្បែងទាញព្រ័ត្រ បានចុះក្នុងបញ្ជីពហុជាតិសាសន៍ តាមសំណើរួមរបស់កម្ពុជា ហ្វីលីពីន វៀតណាម និងសាធារណរដ្ឋកូរ៉េ ក្នុង "បញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ" នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំលើកទី១០ នៃគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលប្រព្រឹត្តទៅនៅទីក្រុងវិនឌុក ប្រទេសណាមីប៊ី។

## ៤. ចាប៉ីដងវែង (៣០ វិច្ឆិកា ២០១៦)

ក្នុងសង្គមខ្មែរ ចាប៉ីជាសិល្បៈដ៏មានប្រជាប្រិយ ដែលអ្នកស្រុកតែងនិយមចូលចិត្តតាំងពីដើមរៀងមក។ សិល្បករចាប៉ីអាចសម្តែងម្នាក់ឯងក៏បាន និងអាចសម្តែងច្រៀងឆ្លងឆ្លើយគ្នាដែលហៅថា "ចាប៉ីឆ្លងឆ្លើយ" ឬច្រៀងដោយមានសិល្បករសម្តែងតាមសាច់រឿងក៏បាន។ ក្រៅពីសម្រាប់កម្សាន្ត ចាប៉ីអាចសម្តែងក្នុងពិធីប្រពៃណីដូចជា ជាវខាន់ស្លា បញ្ជាន់អារក្ស កោរជុក បំបួសនាគ និងពិធីបុណ្យក្នុងទំនៀមសាសនាជាដើម។ មិនតែប៉ុណ្ណោះ ឧបករណ៍ចាប៉ីអាចប្រើក្នុងវង់ភ្លេងអារក្ស និងវង់ភ្លេងការបុរាណទៀតផង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤ ចាប៉ីដងវែងសម្តែងសាច់រឿង



រូបលេខ២៥ ចាប៉ីដងវែងសម្តែងច្រៀងម្នាក់ឯង

ដោយសារតម្លៃលេចធ្លោជាសាកល ចាប៉ីដងវែងត្រូវបានគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី ចុះទៅក្នុង "បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ" របស់អង្គការយូណេស្កូ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្នុងសម័យប្រជុំលើកទី១១ នៅទីក្រុងអាឌីសអាបាបា ប្រទេសអេត្យូពី។

## ៥ ល្ខោនខោលវត្តស្វាយអណ្តែត (២៨ វិច្ឆិកា ២០១៨)

ល្ខោនខោល ជាសិល្បៈបុរាណសម្តែងដោយមនុស្សប្រុស ពាក់មុខខ្នកសម្តែងអន្ទើនានាក្នុងរឿងរាមកេរ្តិ៍ ដោយមានអ្នកពោលដំណើររឿង និងកំដរដោយភ្លេងពិណពាទ្យ។ ល្ខោនខោលវត្តស្វាយអណ្តែត គឺជាសិល្បៈសក្ការៈរបស់ហគមន៍វត្តស្វាយអណ្តែត ដែលស្ថិតក្នុងភូមិតាស្គរ សង្កាត់សារិកាកែវ ក្រុងអរិយក្សត្រ ខេត្តកណ្តាល។ តាមទំនៀមប្រចាំឆ្នាំ ល្ខោនខោលក្រុមនេះតែងមានពិធីសំពះគ្រូសម្តែងថ្វាយបារមីម្តង ក្រោយថ្ងៃចូលឆ្នាំ។



រូបលេខ២៦ ការសម្តែងល្ខោនប្រចាំឆ្នាំថ្វាយបារមី



រូបលេខ២៧ ការសម្តែងក្នុងទិវាវប្បធម៌ជាតិ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាមោទនភាព នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ល្ខោនខោលវត្តស្វាយអណ្ដែត ដែលជាតំណាងល្ខោនខោលទូទាំងប្រទេស ត្រូវបានអង្គការយូណេស្កូអនុម័តយល់ព្រម ចុះក្នុង "បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ" នៅទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីស តាមសេចក្ដីសម្រេច Decision 13.COM.10.a.3 ក្នុងកិច្ចប្រជុំលើកទី១៣ នៃគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់អង្គការយូណេស្កូ។

## ៦. គុនល្បុក្កតោ (២៩ វិច្ឆិកា ២០២២)

គុនល្បុក្កតោ មានឈ្មោះហៅផ្សេងៗគ្នាទៅតាមតំបន់ ហើយការហាត់រៀនក៏ខុសគ្នាដែរ។ គេយល់ថា ក្បាច់គុនល្បុក្កតោមានមូលដ្ឋានពីចម្លាក់តាមប្រាសាទ ជាពិសេសចម្លាក់នៅប្រាសាទបាយ័ន្ត។ ការហាត់ក្បាច់គុននេះ មិនត្រឹមតែផ្ដោតលើការប្រើបច្ចេកទេសរាងកាយ និងទេពកោសល្យរហ័សរហួន ឈ្លាសវៃ ប៉ិនប្រសប់ការពារខ្លួនប៉ុណ្ណោះទេ តែបានបង្រៀនអំពីការគោរព សេចក្ដីថ្លៃថ្នូរ និងវិន័យទៀតផង។ លក្ខណៈពិសេសគុនល្បុក្កតោ គឺការប្រើប្រាស់រាងកាយប្រយុទ្ធដូចជា កណ្ដាប់ដៃ កែងដៃ ជង្គង់ និងជើង ហើយមេគុនខ្លះមានប្រើដំបង ឬដាវជាអាវុធជំនួយផង។



រូបលេខ៨ ការសម្ដែងគុនល្បុក្កតោនៅសាលា



រូបលេខ៩ ការសម្ដែងល្បុក្កតោក្នុងពិធីជាតិ (រូបថត?)

កម្ពុជាបានស្នើចុះគុនល្បុក្កតោ ក្នុងបញ្ជីបេតិកភណ្ឌសម្បត្តិវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ដោយជោគជ័យ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នៅទីក្រុងរ៉ាបាត នៃព្រះរាជាណាចក្រម៉ារ៉ុក ក្នុងកិច្ចប្រជុំលើកទី១៧ នៃសេចក្ដីសម្រេចលេខ 17.COM7.b1។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ៧. ក្រមា (៤ ធ្នូ ២០២៤)

*ក្រមា ឬកន្សែង គឺជាមត៌កវប្បធម៌អរូបីកម្ពុជាទី៧ ដែលចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ នៅទីក្រុងអាសង់ស្យុង សាធារណរដ្ឋប៉ារ៉ាហ្គាយ តាមរយៈសេចក្តីសម្រេចលេខ19.COM 7.b.27។ សង្គមខ្មែរចាត់ទុកក្រមា ជាវត្ថុសំខាន់ភ្ជាប់នូវតម្លៃខ្លឹមសារ និងអត្តសញ្ញាណវប្បធម៌ជ្រាលជ្រៅក្រៃលែង។ ក្នុងជីវភាពប្រចាំ ជាពិសេសចំពោះអ្នកស្រែចម្ការ ក្រមាអាចប្រើសម្រាប់ស្លៀកដណ្តប់ រេចខ្ចប់ ក្រាល ទទូរ ឆ្នួត បង់ក ពានា ។ល។*



*រូបលេខ១០ ចងជាយក្រមា*



*រូបលេខ១១ ក្រមាក្នុងសិល្បៈអង្គការ EPIC Art*

*សរុបសេចក្តីមក ការចុះបញ្ជីមត៌កវប្បធម៌អរូបីក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ ពិតជាបានផ្តល់នូវគុណតម្លៃចំពោះវប្បធម៌ និងសង្គមដែលជាមោទនភាពដ៏ធំធេងសម្រាប់ជាតិ ដ្បិតមត៌កទាំងនោះបានការទទួលស្គាល់ និងលើកតម្លៃលើឆាកអន្តរជាតិ។ ទន្ទឹមនោះ នឹងទទួលបានការអភិរក្ស-ការពារ និងលើកកម្ពស់ការយល់ដឹងកាន់តែទូលំទូលាយផងដែរ៕*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

## ឯកសារយោង

គង់ វីរៈ និង ព្រាប ចាន់ម៉ារ៉ា, ២០០៤, *ស្បែកធំ,* យូណេស្កូ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា, ២០០៩, *ល្ខោនខោលវត្តស្វាយអណ្ដែត,* រៃយំ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា, "របាំបុរាណ", ផ្សាយលើគេហទំព័រ *www.yosothor.org/publications/khmer-renaissance/chapter-three/rbam-boran.html*

សាន ផល្លា, "ល្ខោនព្រះរាជទ្រព្យ" ផ្សាយលើគេហទំព័រ *http://www.yosothor.org/publications/khmer-renaissance/chapter-three/lakorn-phreas-reach-trob.html*

អនុសញ្ញាអង្គការយូណេស្កូ ឆ្នាំ២០០៣ ផ្សាយលើគេហទំព័រ *https://ich.unesco.org/en/basic-texts-00503*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*